ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការឯកជនភាវូបនីយកម្ម នៃរាជាយស្វ័យយានកម្ពុជា លើការងារគ្រប់គ្រង និងប្រតិបត្តិការ និងសេវាផ្សេងៗ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ :** បង្កើតគណៈកម្មការឯកជនភាវូបនីយកម្ម នៃរាជាយស្វ័យយានកម្ពុជាលើការងារគ្រប់គ្រង និងប្រតិបត្តិការ និងសេវាផ្សេងៗ ដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | សេង លឹមនៅ | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម | អ៊ុក ចាន់ | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- | ឯកឧត្តម | អ៊ុក រ៉ាប៊ុន | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤- | ឯកឧត្តម | សំ សុខផល | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |
| ៥- | ឯកឧត្តម | សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦- | ឯកឧត្តម | សយ សុខា | អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |
| ៧- | ឯកឧត្តម | ជា វ៉ាន់ដេត | នាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៨- ឯកឧត្តម | ហ៊ឹង ថូរ៉ាក់ស៊ី | នាយករងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩- ឯកឧត្តម | សុខុម ភគវន្តមុនី | ប្រធានអគ្គនាយកដ្ឋានរាជាយស្វ័យយានកម្ពុជា | សមាជិក |
| ១០- លោក | ការ៉ំង ឈាងខ័ណ្ឌ | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១- លោក | ហ៊្លី អានថ័រនិថ | នាយកខុទ្ទកាល័យក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |

**ប្រការ ២**: គណៈកម្មការ មានភារកិច្ចពិនិត្យការសិក្សាបឋម ការងារជំនាញ និងការងារវាយតម្លៃការធ្វើឯកជនភាវូបនីយកម្មលីសេវាដឹកជញ្ជូន ការងារគ្រប់គ្រង និងប្រតិបត្តិការ និងសេវាផ្សេងៗ ។

**ប្រការ ៣**: គណៈកម្មការ ត្រូវរាយការណ៍អំពីលទ្ធផលនៃការងាររបស់ខ្លួនជូននាយករដ្ឋមន្ត្រីពិនិត្យ និងសម្រេច ។

**ប្រការ ៤**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល** :
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងប្រការ ៤
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com